ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៧ អយក.សណន

# សេចក្តីណែនាំ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ នៅតាមគ្រឹះស្ថានសិក្សាឯកជន សម្រាប់ឆ្នាំសិក្សា២០១៩-២០២០

កន្លងមក ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីណែនាំស្តីពីការអនុវត្តប្រកាសលេខ ១៥៤ អយក.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ សម្រាប់ឆ្នាំសិក្សា២០១៨-២០១៩ និងសេចក្តីណែនាំលេខ ៥១ អយក.សណន ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ។ ដោយសារតែស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ១៩ ក្រសួងអប់រំ យុវជន និងកីឡាបានអនុញ្ញាតឱ្យគ្រឹះស្ថានសិក្សាឯកជនបង្រៀន និងរៀនតាមការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងរៀបចំការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិរៀងៗខ្លួន។ ដើម្បីធានាបាននូវស្តង់ដាគុណភាពនៃការប្រឡង ក្រសួងសូមធ្វើការណែនាំដូចខាងក្រោម៖

## ១. ការដាក់ពាក្យស្នើសុំរៀបចំការប្រឡង

គ្រឹះស្ថានសិក្សាឯកជនត្រូវដាក់ពាក្យស្នើសុំរៀបចំការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិមកក្រសួងតាមរយៈមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ឱ្យបានមុនដំណាច់ខែកក្កដា ឆ្នាំ២០២០ ជាកំហិត ដើម្បីពិនិត្យ និងទទួលស្គាល់។

ក្នុងករណីគ្រឹះស្ថានសិក្សាឯកជនណាដែលមិនមានលទ្ធភាពរៀបចំការប្រឡងដោយខ្លួនឯង ត្រូវរង់ចាំចូលរួមប្រឡងជាមួយសិស្សនៃគ្រឹះស្ថានសិក្សាសាធារណៈនៅពេលក្រោយ តាមការជូនដំណឹងរបស់ក្រសួង។

## ២. គោលការណ៍នៃការចុះឈ្មោះប្រឡង និងបេក្ខភាពប្រឡង

### ២.១. សំណុំលិខិតចុះឈ្មោះប្រឡង

សំណុំលិខិតដាក់ពាក្យសុំប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ រួមមាន ៖

- ពាក្យសុំប្រឡងរបស់បេក្ខជន ចំនួន ១ច្បាប់ (បំពេញដោយដៃបេក្ខជនផ្ទាល់)
- សលាកបត្រឯកត្តជនទំហំ ១៥ស.ម គុណនឹង ២១ស.ម មានបិទរូបថតថ្មី ថតចំពីមុខទំហំ ៤ស.ម គុណនឹង ៦ស.ម ចំនួន ០២សន្លឹក
- បង្កាន់ដៃបង់សិទ្ធិប្រឡង ០១សន្លឹក (តម្លៃ ១០០០រៀល)

- រូបថត ថតថ្មី ថតចំពីមុខទំហំ ៤ស.ម គុណនឹង៦ស.ម " រូបថតដែលបានបិទលើសលាកបត្រឯកត្តជន " ចំនួន ០២សន្លឹក
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬសំបុត្របញ្ជាក់កំណើត ចំនួន ០១សន្លឹក (ថតចម្លង)
- សៀវភៅសិក្ខាគារិក ។

ចំពោះសន្លឹកបង្កាន់ដៃបង់សិទ្ធិប្រឡង នាយក នាយិកាគ្រឹះស្ថានសិក្សាឯកជន ត្រូវស្នើសុំពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងត្រូវប្រមូលថវិកាដែលទទួលបានពីការបង់ថ្លៃសិទ្ធិប្រឡងនេះជូនវិញ ដើម្បីមន្ទីរយកទៅបង់បន្តនៅរតនាគារ។

### ២.២. បេក្ខភាពប្រឡង

សិស្សគ្រឹះស្ថានសិក្សាឯកជនដែលអាចដាក់ពាក្យសុំចុះឈ្មោះប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- បានរៀននៅមធ្យមសិក្សាបឋមភូមិគ្រប់កម្រិតថ្នាក់
- កំពុងរៀននៅថ្នាក់ទី៩
- បានគោរពត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុង សម្រាប់គ្រឹះស្ថានមធ្យមសិក្សា
- ត្រូវបានវាយតម្លៃផ្នែកសីលធម៌ប្រចាំឆ្នាំ ចាប់ពីកម្រិតមធ្យមឡើងទៅ
- មានមធ្យមភាគពិន្ទុប្រចាំឆ្នាំចាប់ពី ២៥,០០ ឡើងទៅ។

### ២.៣. បញ្ជីឈ្មោះបេក្ខជនតាមបន្ទប់ប្រឡង

គ្រឹះស្ថានសិក្សាឯកជនត្រូវ៖

- ផ្តល់សំណុំលិខិតដាក់ពាក្យសុំប្រឡងមកមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត ដើម្បីពិនិត្យបេក្ខភាពប្រឡង។ ក្រោយពិនិត្យបេក្ខភាពរួច មន្ទីរនឹងផលិតបញ្ជីឈ្មោះបេក្ខជនតាមបន្ទប់ប្រឡង តាមគ្រឹះស្ថានសិក្សាឯកជននីមួយៗ ជាទម្រង់ PDF ក្នុង១បន្ទប់មានបេក្ខជនពី ១០ ទៅ ១៥នាក់ ហើយបញ្ជូនត្រឡប់ទៅឱ្យគ្រឹះស្ថានសិក្សានីមួយៗបោះពុម្ពដោយខ្លួនឯងដើម្បីប្រើប្រាស់
- ជានាអនុវត្តវិធានការសុវត្ថិភាពសុខភាពរបស់ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក (WHO)។

**សម្គាល់៖**

- គ្រឹះស្ថានសិក្សាឯកជនដែលបានដាក់ពាក្យសុំចុះឈ្មោះប្រឡងជាមួយមន្ទីរ ត្រូវគោរពតាមគោលការណ៍បេក្ខភាពប្រឡងដូចកំណត់ខាងលើ ដោយមិនអនុញ្ញាតឱ្យមានបេក្ខជនសេរីនទេ
- សិស្សគ្រឹះស្ថានសិក្សាឯកជនដែលបានប្រឡងរួចហើយ នឹងត្រូវលុបឈ្មោះចេញពីបេក្ខជនប្រឡងថ្នាក់ជាតិជាមួយក្រសួង។

## ៣. ការកំណត់សម័យប្រឡង និងមណ្ឌលប្រឡង

### ៣.១. ការកំណត់សម័យប្រឡង

សម័យប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ត្រូវបានកំណត់យក**ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០**។

### ៣.២. ការកំណត់មណ្ឌលប្រឡង និងបន្ទប់ប្រឡង

គ្រឹះស្ថានសិក្សាឯកជននីមួយៗត្រូវរៀបចំមណ្ឌលប្រឡង និងបញ្ជូនមកក្រសួងអប់រំ យុវជន និងកីឡា តាមរយៈមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីពិនិត្យ និងសម្រេច។

## ៤. ការរៀបចំវិញ្ញាសា ការកំណត់ថេរវេលា និងរបបពិន្ទុ

### ៤.១ វិញ្ញាសា ថេរវេលា និងរបបពិន្ទុ

| | | | |
|---|---|---|---|
| – តែងសេចក្តី | រយៈពេល ៩០ នាទី | ពិន្ទុពី ០ ដល់ ៦០ |
| – ការសរសេរតាមអាន | រយៈពេល ៦០ នាទី | ពិន្ទុពី ០ ដល់ ៤០ |
| – គណិតវិទ្យា | រយៈពេល ១២០ នាទី | ពិន្ទុពី ០ ដល់ ១០០ |
| – រូបវិទ្យា | រយៈពេល ៤៥ នាទី | ពិន្ទុពី ០ ដល់ ៣៥ |
| – គីមីវិទ្យា | រយៈពេល ៣០ នាទី | ពិន្ទុពី ០ ដល់ ២៥ |
| – ជីវវិទ្យា | រយៈពេល ៤៥ នាទី | ពិន្ទុពី ០ ដល់ ៣៥ |
| – ផែនដី និងបរិស្ថានវិទ្យា | រយៈពេល ៣០ នាទី | ពិន្ទុពី ០ ដល់ ២៥ |
| – សីលធម៌-ពលរដ្ឋវិជ្ជា | រយៈពេល ៤៥ នាទី | ពិន្ទុពី ០ ដល់ ៣៥ |
| – ភូមិវិទ្យា | រយៈពេល ៤០ នាទី | ពិន្ទុពី ០ ដល់ ៣២ |
| – ប្រវត្តិវិទ្យា | រយៈពេល ៤០ នាទី | ពិន្ទុពី ០ ដល់ ៣៣ |
| – ភាសាបរទេស | រយៈពេល ៤៥ នាទី | ពិន្ទុពី ០ ដល់ ៥០ |

**សម្គាល់៖** ថេរវេលានៃវិញ្ញាសានីមួយៗ គិតពីពេលកត់វិញ្ញាសាលើក្តារខៀនចប់។

### ៤.២. ការតាក់តែង រៀបចំ និងគ្រប់គ្រងវិញ្ញាសា

វិញ្ញាសាទាំងអស់ត្រូវបានជ្រើសរើស តាក់តែង រៀបចំ និងគ្រប់គ្រងដោយគ្រឹះស្ថានសិក្សានីមួយៗ។ ការតាក់តែង រៀបចំ និងគ្រប់គ្រងវិញ្ញាសាត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- ការតាក់តែងវិញ្ញាសាប្រឡង ត្រូវយកតាមកម្មវិធីសិក្សាថ្នាក់ទី៩នៃមធ្យមសិក្សាបឋមភូមិ និងយកតាមគំរូកម្រងវិញ្ញាសា ដែលក្រសួងអប់រំ យុវជន និងកីឡា ចេញកន្លងមកធ្វើជាស្តង់ដាគោល ហើយត្រូវទទួលខុសត្រូវចំពោះមុខក្រសួងក្នុងការគ្រប់គ្រងប្រធានវិញ្ញាសា
- វិញ្ញាសាគ្រប់មុខវិជ្ជា ត្រូវចែកទៅតាមចំនួនបន្ទប់ប្រឡង ដើម្បីឱ្យអនុរក្សចម្លងដាក់លើក្តារខៀន ដោយមានអ្នកត្រួតពិនិត្យឱ្យបានត្រឹមត្រូវ លើកលែងតែអត្ថបទសរសេរតាមអានប៉ុណ្ណោះ
- បន្ទាប់ពីដំណើរការសរសេរនៃវិញ្ញាសានីមួយៗ ត្រូវរៀបចំដាក់ក្នុងស្រោមបិទសម្ងាត់ Sceller រួចផ្តល់ជូនលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡាដោយផ្ទាល់ ដើម្បីពិនិត្យលើកម្រិតវិញ្ញាសា
- គ្រឹះស្ថានសិក្សាឯកជននីមួយៗ មិនអាចចេញវិញ្ញាសាដូចគ្នាបានទេ
- បេក្ខជនទាំងឡាយ អាចជ្រើសរើសយកភាសាបរទេសតែមួយប៉ុណ្ណោះ ក្នុងចំណោមភាសាបារាំង ឬភាសាអង់គ្លេស។ ការជ្រើសរើសភាសាបរទេស ត្រូវយកតាមភាសាដែលបេក្ខជនបានជ្រើសរើសពេលប្រឡងឆមាសលើកទី១ និងប្រឡងឆមាសលើកទី២

- ពិន្ទុភាសាបរទេសត្រូវគិតយកតែពិន្ទុ ដែលបេក្ខជនធ្វើបានលើសពី ២៥ ទៅបូកបញ្ចូលជាមួយពិន្ទុមុខវិជ្ជាផ្សេងៗទៀត
- សិស្សគ្រឹះស្ថានសិក្សាឯកជនដែលបានរៀនមុខវិជ្ជានានាជាភាសាអង់គ្លេស លើកលែងមុខវិជ្ជាភាសាខ្មែរ មិនតម្រូវឱ្យប្រឡងវិញ្ញាសាភាសាបរទេសទេ
- សិស្សគ្រឹះស្ថានសិក្សាឯកជនដែលបានរៀនមុខវិជ្ជានានាជាភាសាអង់គ្លេស អនុរក្សត្រូវបកប្រែវិញ្ញាសាគ្រប់មុខវិជ្ជាជាភាសាអង់គ្លេស លើកលែងតែវិញ្ញាសាតែងសេចក្តី និងការសរសេរតាមអាន ហើយត្រូវទូទាត់រយៈពេលបកប្រែវិញ្ញាសានោះ តែមិនឱ្យប៉ះពាល់ដល់ការប្រព្រឹត្តទៅនៃវិញ្ញាសាបន្ទាប់។

### ៤.៣ ពិន្ទុកំណត់ឱ្យជាប់ និងនិទ្ទេស

- ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ រយៈពេលប្រឡង ២ថ្ងៃស្មើនឹង ៥៩០នាទី មានរបបពិន្ទុអតិបរមា ៤៤៥ពិន្ទុ និងរបបពិន្ទុប្រចាំឆ្នាំ ១០០ពិន្ទុ។ ពិន្ទុសរុប : ៤៤៥ + ១០០ = ៥៤៥ ប៉ុន្តែដោយភាសាបរទេសជាវិញ្ញាសាតាមស្ម័គ្រ ដូចនេះពិន្ទុប្រឡងជាប់គឺ ៥៤៥ ដក ២៥ រួចចែកនឹង ២ ស្មើនឹង ២៦០ពិន្ទុ
- ចំពោះបេក្ខជនអវត្តមាន ចាប់ពីមួយវិញ្ញាសាឡើងទៅត្រូវកំណត់ឱ្យធ្លាក់ជាស្វ័យប្រវត្តិ និងត្រូវចុះអក្សរ "A" នៅក្នុងតារាងស្រង់ពិន្ទុ ដោយមិនចាំបាច់បូកពិន្ទុដាក់ក្នុងខ្ទង់ពិន្ទុសរុបឡើយ
- ចំពោះបេក្ខជនដែលមិនបានប្រគល់សន្លឹកកិច្ចការវិញ្ញាសាណាមួយដល់គណៈមេប្រយោគត្រូវចាត់ទុកបេក្ខជននោះអវត្តមានចំពោះវិញ្ញាសានោះហើយត្រូវអនុវត្តដូចករណីបេក្ខជនអវត្តមានដូចបានរៀបរាប់ខាងលើ។ ចំពោះបេក្ខជនដែលមកប្រឡងគ្រប់វិញ្ញាសាទាំងអស់លើកលែងតែវិញ្ញាសាភាសាបរទេសដែលជាវិញ្ញាសាតាមស្ម័គ្រ ត្រូវបូកពិន្ទុ និងកំណត់ឱ្យជាប់តាមធម្មតា ទោះបីមានវិញ្ញាសាណាមួយ ឬច្រើនបានពិន្ទុសូន្យក៏ដោយ
- និទ្ទេសត្រូវបានកំណត់ដូចតទៅ៖

| | | | | | |
|---|---|---|---|---|---|
| * | ចាប់ពីពិន្ទុ | ២៦០ | ទៅពិន្ទុ ៣៣៧ | និទ្ទេស | : មធ្យម |
| * | ចាប់ពីពិន្ទុ | ៣៣៨ | ទៅពិន្ទុ ៤១៥ | និទ្ទេស | : ល្អបង្គួរ |
| * | ចាប់ពីពិន្ទុ | ៤១៦ | ឡើងទៅ | និទ្ទេស | : ល្អ។ |

## ៥. តារាងប្រព្រឹត្តទៅនៃវិញ្ញាសា

**ថ្ងៃចន្ទ ទី០៣ ខែសីហា ឆ្នាំ២០២០**

**ពេលព្រឹក ៖**

| | | | | | | |
|---|---|---|---|---|---|---|
| ម៉ោង | ០៧ : ៣០ | ដល់ម៉ោង | ០៩ : ០០ | : | តែងសេចក្តី | (៩០នាទី) |
| ម៉ោង | ០៩ : ៣០ | ដល់ម៉ោង | ១០ : ០០ | : | គីមីវិទ្យា | (៣០នាទី) |
| ម៉ោង | ១០ : ៣០ | ដល់ម៉ោង | ១១ : ០០ | : | ផែនដី និងបរិស្ថានវិទ្យា | (៣០នាទី) |

**ពេលរសៀល ៖**

| | | | | | | |
|---|---|---|---|---|---|---|
| ម៉ោង | ១៤ : ០០ | ដល់ម៉ោង | ១៤ : ៤៥ | : | រូបវិទ្យា | (៤៥នាទី) |

ម៉ោង ១៥ : ១៥ ដល់ម៉ោង ១៥ : ៥៥ : ភូមិវិទ្យា (៤០នាទី)

ម៉ោង ១៦ : ២៥ ដល់ម៉ោង ១៧ : ១០ : សីលធម៌-ពលរដ្ឋវិជ្ជា (៤៥នាទី)

**ថ្ងៃអង្គារ ទី០៤ ខែសីហា ឆ្នាំ២០២០**

**ពេលព្រឹក ៖**

ម៉ោង ០៧ : ៣០ ដល់ម៉ោង ០៩ : ៣០ : គណិតវិទ្យា (១២០នាទី)

ម៉ោង ១០ : ០០ ដល់ម៉ោង ១១ : ០០ : ការសរសេរតាមអាន (៦០នាទី)

**ពេលរសៀល ៖**

ម៉ោង ១៤ : ០០ ដល់ម៉ោង ១៤ : ៤៥ : ជីវវិទ្យា (៤៥នាទី)

ម៉ោង ១៥ : ១៥ ដល់ម៉ោង ១៥ : ៥៥ : ប្រវត្តិវិទ្យា (៤០នាទី)

ម៉ោង ១៦ : ២៥ ដល់ម៉ោង ១៧ : ១០ : ភាសាបរទេស (៤៥នាទី)

## ៦. ការរៀបចំគណៈមេប្រយោគ និងគណៈកម្មការផ្សេងៗ

ការប្រើប្រាស់គណៈមេប្រយោគ និងគណៈកម្មការផ្សេងៗ ត្រូវរៀបចំតាមលំនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលធ្លាប់អនុវត្តកន្លងមក។

ក្នុងដំណើរការសំណេរ គ្រឹះស្ថានសិក្សា ត្រូវរៀបចំគណៈមេប្រយោគ និងគណៈកម្មការផ្សេងៗ ដូចជា៖ ប្រធាន អនុប្រធានមណ្ឌលសំណេរ គណៈកម្មការត្រួតពិនិត្យតាមអគារ គណៈកម្មការកណ្តាល គណៈកម្មការអនុរក្ស គណៈកម្មការបង្ការនិងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩។ល។

ក្នុងដំណើរការកំណែ ស្រង់ បូកពិន្ទុ និងចុះជាប់ធ្លាក់ គ្រឹះស្ថានសិក្សាត្រូវរៀបចំគណៈមេប្រយោគ និងគណៈកម្មការផ្សេងៗ ដូចជា៖ ប្រធាន អនុប្រធានមណ្ឌលកំណែ គណៈកម្មការកណ្តាល គណៈកម្មការបែងចែកសន្លឹកកិច្ចការ ប្រធាន អនុប្រធាន សមាជិកគណៈកម្មការកំណែ គណៈកម្មការស្រង់ បូកពិន្ទុ ផ្ទៀងផ្ទាត់ពិន្ទុ និងគូសជាប់ធ្លាក់ និងគណៈកម្មការបង្ការនិងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩។ល។

ក្រសួង និងមន្ទីរនឹងចុះពិនិត្យដំណើរការប្រឡងតាមការចាំបាច់ ដើម្បីធានាគុណភាពនៃការប្រឡង។

## ៧. ការផ្តល់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ

គ្រឹះស្ថានសិក្សានីមួយៗ ជាអ្នកចេញសញ្ញាបត្រ និងចុះហត្ថលេខាលើសញ្ញាបត្រដោយខ្លួនឯង ហើយក្រសួងនឹងទទួលស្គាល់ក្រោយពេលពិនិត្យឃើញថាការប្រឡងប្រព្រឹត្តទៅស្របតាមការណែនាំរបស់ក្រសួង និងប្រធានវិញ្ញាសាមានកម្រិតស្តង់ដាប្រហាក់ប្រហែលឆ្នាំកន្លងមក។ ក្នុងករណីចាំបាច់ ក្រសួងនឹងចុះអធិការកិច្ច ដើម្បីធានានូវគុណភាពនៃសញ្ញាបត្រ។

## ៨. ការផ្តល់សំណុំលិខិតមកនាយកដ្ឋានកិច្ចការប្រឡង និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត

គ្រឹះស្ថានសិក្សាឯកជននីមួយៗត្រូវផ្តល់សំណុំលិខិតខាងក្រោមនេះ មកមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ១ច្បាប់(លើកលែងវិញ្ញាសាគ្រប់មុខវិជ្ជា) និងមកនាយកដ្ឋានកិច្ចការប្រឡង (ការិយាល័យប្រឡងចំណេះទូទៅ និងអប់រំបច្ចេកទេស ទូរស័ព្ទ៖ ០២៣ ៧២៦ ៧៩៣) Telegram: ការិ.ប្រឡង.ចទ-អបទ

(០១២ ៧៣ ៦៧ ៦៧) ១ច្បាប់។

**៨.១. មុនដំណាច់ខែកក្កដា ឆ្នាំ២០២០**

- ពាក្យសុំរៀបចំការប្រឡងរបស់នាយក នាយិកាគ្រឹះស្ថានសិក្សាឯកជន
- សំណើមណ្ឌលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ។

**៨.២. មុនថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០**

- បញ្ជីគូសជាប់ ធ្លាក់ ២ច្បាប់ (Hard និង Soft Copy)
- តារាងស្រង់ពិន្ទុ ២ច្បាប់ (Hard និង Soft Copy)
- ស្ថិតិបេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ២ច្បាប់ (Hard និង Soft Copy)។

ទទួលបានសេចក្តីណែនាំនេះ សូមឯកឧត្តម លោកជំទាវ លោក លោកស្រីនាយក នាយិកាគ្រឹះស្ថានសិក្សាឯកជន និងលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  «ដើម្បីជូនជ្រាបជាព័ត៌មាន»
- សាលារាជធានី ខេត្ត
- អង្គភាពពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួង.អយក
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
  «ដើម្បីសហការអនុវត្ត»
- ឯកសារ-កាលប្បវត្តិ នា.កប្រឡ